multi cultural communication

**KHMER / ខ្មែរ**
**1 June 2002**
**[BHC-6115]**

# ការចាក់ថ្នាំសំរាប់ទារកដែលទើបនឹងកើត - ហេតុដូចម្តេចបានជាថ្នាំទាំងនេះជាការសំខាន់
# Injections for newborn babies - why they're important

មាតាបិតាត្រូវដឹងអំពីការចាក់ថ្នាំ២មុខសំរាប់ទារកដែលទើបនឹងកើត។ មួយគឺការចាក់ថ្នាំវីតាមីនពិសេសម្យ៉ាង ហៅ vitamin K សំរាប់ការពារនូវលក្ខណៈមួយដែលកម្រកើតមានឡើង តែមានសភាពធ្ងន់ធ្ងរហៅថា "ការចេញឈាមព្រោះខ្វះជាតិវីតាមីន K" (Vitamin K Deficiency Bleeding អក្សរកាត់ VKDB)។ ការចាក់ថ្នាំមួយទៀតគឺសំរាប់ការពារទល់និងជម្ងឺថ្លើម Hepatitis B ។ ទារកអាចទទួលការចាក់ថ្នាំទាំង២មុខនេះនៅមន្ទីរពេទ្យក្រោយពេលដែលទើបនឹងកើតរួច។ ការចាក់ថ្នាំនេះនៅក្នុងមន្ទីរពេទ្យសាធារណៈ អត់មានគិតថ្លៃឡើយ។

**តើហេតុដូចម្តេចបានជាទារកត្រូវការវីតាមីន K ?**

បើកាលណាខ្វះជាតិវីតាមីន K ទារកអាចមានគ្រោះថ្នាក់កើត"បញ្ហាចេញឈាមព្រោះខ្វះជាតិវីតាមីន K (VKDB)"។ នេះអាចបណ្តាលឲ្យមានការចេញឈាមខ្លាំង ដែលអាចទាក់ទងដល់ខួរក្បាល។

**តើទារកទាំងអស់ដែលទើបនឹងកើត ត្រូវការវីតាមីន K ឬ ?**

ពិតហើយ។ ទារកដែលទើបនឹងកើត អាចមិនមានវីតាមីន K គ្រប់គ្រាន់ក្នុងសរីរាង្គកាយសំរាប់ការពារកុំឲ្យមាន"បញ្ហាចេញឈាមព្រោះខ្វះជាតិវីតាមីន K"។ ប៉ុន្តែកាលណាមានអាយុដល់៦ខែ តាមធម្មតារាងកាយទារកបង្កើតវីតាមីននោះគ្រប់គ្រាន់ដោយខ្លួនឯង។

**តើតាមធម្មតាគេឲ្យវីតាមីន K តាមការចាក់ថ្នាំឬ ?**

គេអាចឲ្យតាមការចាក់ថ្នាំ ឬជាថ្នាំគ្រាប់លប។ ការចាក់ថ្នាំវាជាការងាយស្រួលជាង ពីព្រោះគេចាក់តែម្តង ហើយមានឥទ្ធិពលជាច្រើនខែ។

ទារកត្រូវការថ្នាំចាក់ប្រសិនបើ ៖

- ទារកនោះកើតមិនគ្រប់ខែ ឬឈឺ
- ម្តាយញ៉ាំថ្នាំសំរាប់ជម្ងឺឆ្កួតជ្រូក(Epilepsy), កកឈាម (Blood clots), ឬមានជម្ងឺរបេង។ (ត្រូវប្រាប់វេជ្ជបណ្ឌិតឬឆ្មបឲ្យដឹងបើកាលណាអ្នកប្រើថ្នាំណាមួយនោះ)។

លោកអ្នកអាចលេបថ្នាំវីតាមីន K បាន ក៏ប៉ុន្តែវាមិនមានឥទ្ធិពលបានយូរដូចថ្នាំចាក់នោះទេ។ មានន័យថា ទារកនោះត្រូវលេប៣លើក ៖

- នៅពេលកើត
- ៣ឬ៥ថ្ងៃក្រោយពេលកើត
- នៅពេលអាយុបាន៤អាទិត្យ។

**សេចក្តីកត់សំគាល់** ៖

**ការលេបលើកទី៣ គឺជាការសំខាន់ណាស់ដែលមាតាបិតាត្រូវចងចាំ  ព្រោះបើមិនដូច្នោះទេ ទារកនោះអាចមិនបានទទួលភាពការពារគ្រប់គ្រាន់ទេ។**

ការលេបថ្នាំលើកណាក៏ដោយ ក៏ត្រូវតែធ្វើឡើងវិញដែរ បើទារកនោះក្អួត។

**តើវីតាមីន K មានធ្វើទុក្ខអ្វីដែរឬទេ** ?

នៅក្នុងប្រទេសអូស្ត្រាលី គេបានឲ្យវីតាមីន K ដល់ទារកតាំងពីឆ្នាំ ១៩៨០ ហើយ“អាជ្ញាធរសុខាភិបាលប្រទេសអូស្ត្រាលី” មានជំនឿថាថ្នាំនេះគ្មានគ្រោះថ្នាក់ទេ។ ទោះបីការសិក្សាមួយបានអោយដឹងថា មានការទាក់ទងរវាងការចាក់ថ្នាំវីតាមីន K និងជម្ងឺមហារីកក្នុងវ័យកុមារភាពក៏ដោយ ក៏មានការសិក្សាចំនួន៦ផ្សេងទៀតដែលយល់ថាគ្មានការទាក់ទងនឹងគ្នាទេ។

**តើខ្ញុំត្រូវតែយល់ព្រមឲ្យវីតាមីន K ដល់កូនខ្ញុំឬ** ?

នេះជាការសំរេចចិត្តរបស់លោកអ្នក។ ក៏ប៉ុន្តែវេជ្ជបណ្ឌិតឲ្យឱវាទម៉ឺងម៉ាត់ថា គួរឲ្យវីតាមីន K ដល់ទារកទាំងអស់ ដោយរាប់បញ្ចូលទាំងទារកដែលឈឺ ឬមានការវះកាត់ (រួមទាំងការកាត់ចុងលិង្គ Circumcission)។ មាតាបិតាដែលសំរេចមិនព្រមឲ្យវីតាមីន K ទៅកូន គួរប្រយ័ត្នសង្កេតមើលនូវរោគសញ្ញានៃលក្ខណៈចេញឈាមព្រោះខ្វះវីតាមីន K ។ រោគសញ្ញនេះមានរាប់បញ្ចូលទាំង ៖

- ការចេញឈាមឬជាំដោយគ្មានមូលហេតុ
- ការដែលស្បែកឡើងលឿង ឬភ្នែកឡើងស **ក្រោយពេលដែលកូនអាយុបាន៣អាទិត្យ** ។

ទារកដែលមានរោគសញ្ញានេះ ត្រូវតែយកទៅជួបវេជ្ជបណ្ឌិត (ទោះបីទារកនោះបានទទួលវីតាមីន K ក្តី)។

**ហេតុដូចម្តេចបានជាទារកត្រូវចាក់ថ្នាំបង្ការជម្ងឺរលាកថ្លើម Hepatitis B)** ?

ជម្ងឺរលាកថ្លើម Hepatitis B ជាជម្ងឺធ្ងន់ធ្ងរមួយ ដែលបណ្តាលមកពីមេរោគធ្វើទុក្ខដល់ថ្លើម។ ជនខ្លះដែលមានជម្ងឺនេះអាចគ្មានរោគសញ្ញា ឬមានរោគសញ្ញាស្រាលប៉ុណ្ណោះ។ ក៏ប៉ុន្តែក្នុងចំណោមជនដែលមានជម្ងឺរលាកថ្លើម មានចំនួនរហូតដល់ទៅ ២៥ភាគរយដែលថ្ងៃក្រោយទៅ ថ្លើមអាចចុះដុនដាបធ្ងន់ធ្ងរខ្លាំង ជាពិសេសចំពោះអ្នកដែលកើតជម្ងឺ Hepatitis B ពីក្មេង។ ការចាក់ថ្នាំបង្ការអាចទប់ទល់បញ្ហានេះបាន។

**តើជម្ងឺរលាកថ្លើម Hepatitis B ឆ្លងតាមរបៀបណា** ?

មេរោគជម្ងឺថ្លើមរស់នៅក្នុងទឹកល្បាយនៃសរីរាង្គកាយ (ឈាម, ទឹកមាត់ និងទឹកកាម)។ ទារកដែលមានម្តាយកើតជម្ងឺ Hepatitis B ច្រើនមានគ្រោះថ្នាក់ឆ្លងជម្ងឺនេះនៅពេលសំរាលកូន។

របៀបផ្សេងទៀតដែលអាចឆ្លងជម្ងឺ Hepatitis B មាន ៖

- បើឈាមរបស់អ្នកមានជម្ងឺនេះជួបប៉ះឈាមរបស់លោកអ្នក។ នេះរួមទាំង៖ ការប៉ះតាមរយៈដាច់រលាត់ស្បែក, ការប៉ះតាមរយៈការប្រើម្ជុលឬគ្រឿងចាក់ដែលមានមេរោគនោះនៅពេលប្រើចាក់គ្រឿងញៀន, ការប៉ះតាមរយៈការប្រើគ្រឿងឬម្ជុលសំរាប់ចោះរាងកាយ ដូចជាការសាក់ខ្លួនជាដើម។
- តាមរយៈការសេពកាមជាមួយជនដែលមានមេរោគនេះ។

<u>តើហេតុដូចម្តេចបានជាត្រូវចាក់ថ្នាំបង្ការនៅពេលកើត</u> ?

ការចាក់ថ្នាំបង្ការជម្ងឺ Hepatitis B ឲ្យទៅទារកនៅពេលកើតភ្លាមគឺជារឿងសំខាន់ដែលត្រូវ ដើម្បីធ្វើអោយថ្នាំបង្ការនេះមានប្រសិទ្ធិភាពខ្លាំងបំផុត។ ទារកត្រូវការការចាក់ថ្នាំបង្ការជម្ងឺ Hepatitis B ៣ដងថែមទៀត – ម្តងនៅពេលកូនបានអាយុ២ខែ, ម្តងនៅពេលអាយុ៤ខែ នឹងម្តងទៀតនៅពេល៦ឬ១២ខែ។ គេចាក់ថ្នាំបង្ការនេះនៅពេលធ្វើការចាក់ថ្នាំបង្ការជម្ងឺផ្សេងៗទៀត។

<u>តើកូនអ្នកត្រូវតែចាក់ថ្នាំបង្ការឬ</u> ?

វាជាការសំរេចចិត្តរបស់លោកអ្នក ក៏ប៉ុន្តែអាជ្ញាធរសុខាភិបាលឲ្យឱវាទខ្លាំងក្លាក្នុងចំណុចនេះ។

<u>តើការចាក់ថ្នាំបង្ការជម្ងឺ **Hepatitis B** អាចបណ្តាលឲ្យមានបញ្ហាអ្វីដែរឬទេ</u> ?

កម្រមានធ្វើទុក្ខអ្វីខ្លាំងណាស់។ ភាពធ្វើទុក្ខធម្មតាដែលច្រើនមាន ដូចជា ការឈឺកន្លែងចាក់ថ្នាំ គ្រុនក្តៅមធ្យម, និងការឈឺសន្លាក់ដៃជើង។ បើលោកអ្នកមានការព្រួយបារម្ភ គួរទៅជួបវេជ្ជបណ្ឌិត។

ប្រសិនបើលោកអ្នកមានការពិបាកក្នុងការទូរស័ព្ទជាភាសាអង់គ្លេស សូមលោកអ្នកទាក់ទងទៅសេវាបកប្រែភាសា (**TIS**) តាមរយៈលេខ 13 1 450។

លោកអ្នកអាចយកព័ត៌មានផ្នែកសុខភាពបន្ថែមទៀតជាភាសាខ្មែរ ពីវិបសាយរបស់អង្គការ **Multicultural Communication** នៅឯ: **http://mhcs.health.nsw.gov.au**

លេខទូរស័ព្ទទាំងនេះត្រឹមត្រូវនៅពេលបោះពុម្ពផ្សាយ ក៏ប៉ុន្តែអាចមិនបានមានការកែតម្រូវឲ្យទាន់កាលៈទេសៈ។ លោកអ្នកប្រហែលត្រូវមើលបញ្ជាក់លេខនៅក្នុង“សៀវភៅទូរស័ព្ទ”(Telephone Directory)៕